ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ....៩៤៣៩.......អពដ

សភាពាណិជ្ជកម្ម រាជធានីភ្នំពេញ
ចូល
លេខ: ២៣៩
ថ្ងៃទី១៨ ម៉ោង១១:៤០
បញ្ជូន

L20200406001 | TD3402

ថ្ងៃអង្គារ ៧កើត ខែចេត្រ ឆ្នាំជូត ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

## ជម្រាបជូន
## អ្នកឧកញ៉ា ប្រធានសភាពាណិជ្ជកម្មកម្ពុជា

**កម្មវត្ថុ ÷** ករណីសំណើសុំរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ ដោយអនុវត្តតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (CIAS) និងស្នើសុំការផ្តល់ការណែនាំបន្ថែមអំពីការរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២០ទៅមុខ ដោយអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនិងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) របស់សភាពាណិជ្ជកម្មកម្ពុជា។

**យោង ÷**
- ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងធ្វើវិសោធនកម្មបន្តបន្ទាប់
- លិខិតលេខ ០០៤៣/២០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់សភាពាណិជ្ជកម្មកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបអ្នកឧកញ៉ាអគ្គនាយក ជ្រាបថា ដោយសមាគមធនាគារនៅកម្ពុជា (ស.ធ.ក) មានបំណងស្នើសុំការសម្របសម្រួលពីអគ្គនាយកដ្ឋានពន្ធដារ ក្នុងការអនុវត្តកាតព្វកិច្ចការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ ដោយអនុវត្តតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (CIAS) ដោយហេតុថា ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានតម្រូវឱ្យគ្រប់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ត្រូវអនុវត្តតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (CIFRS) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

ឆ្លើយតបនឹងសំណើរបស់សភាពាណិជ្ជកម្មកម្ពុជា អគ្គនាយកដ្ឋានពន្ធដារអនុញ្ញាតឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ អាចរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩ ដោយអនុវត្តតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (CIAS)។ ដោយឡែក សម្រាប់ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២០ អគ្គនាយកដ្ឋានពន្ធដារសូមបញ្ជាក់ជូនថា គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវអនុវត្តតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (CIFRS) ឱ្យបានស្របទៅតាមការណែនាំរបស់ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកឧកញ៉ាប្រធានជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមអ្នកឧកញ៉ា ប្រធានសភាពាណិជ្ជកម្មកម្ពុជា ទទួលនូវការរាប់អាន ពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ចម្លងជូន ÷
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានសវនកម្មសហគ្រាស
- (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ